ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

លេខ : ១៥៩ ឈ.ឆល.អក.មពស

ថ្ងៃអង្គារ ០៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតនៅប្រទេសចិនឆ្នាំ២០១៨
## នៅសាកលវិទ្យាល័យ Guangxi University

អគ្គិសនីកម្ពុជា សូមជម្រាបដល់និយោជិតអគ្គិសនីកម្ពុជាទាំងអស់ឲ្យបានជ្រាបថាក្នុងឆ្នាំ២០១៨ ក្រុមហ៊ុន China Southern Power Grids (CSG) បានផ្តល់អាហារូបករណ៍សិក្សាថ្នាក់អនុបណ្ឌិត ដល់ មន្ត្រីក្រសួងរ៉ែនិងថាមពល និងនិយោជិតអគ្គិសនីកម្ពុជា **ចំនួន១០កន្លែង** ទៅសិក្សានៅប្រទេសចិនលើមុខជំនាញ ចំនួន០៣គឺ (១)Architecture and Civil Engineering Master Program(២)Master Degree for Electrical Engineering (៣)Master Degree Program in Water Conservancy Engineering ដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

**១. លក្ខខណ្ឌនៃការជ្រើសរើស៖**

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឬវិស្វករដែលពាក់ព័ន្ធនឹងជំនាញ (ភ្ជាប់ព្រឹត្តិបត្រពិន្ទុ)
- ត្រូវមានចំណេះដឹងភាសាអង់គ្លេស និងភាសាចិនជាអាទិភាព
- ត្រូវមានលិខិតបញ្ជាក់ពីសាស្ត្រាចារ្យជាភាសាអង់គ្លេសឬភាសាចិនចំនួនពីររូប(ពីរច្បាប់ផ្សេងគ្នា)
- ត្រូវមានអាយុមិនលើសពី៤៥ឆ្នាំ
- ត្រូវភ្ជាប់មកនូវលិខិតបញ្ជាក់សុខភាព និងលិខិតឆ្លងដែនថតចំលង
- ត្រូវភ្ជាប់មកនូវពាក្យស្នើសុំអាហារូបករណ៍
- ត្រូវភ្ជាប់មកនូវពាក្យលិខិតវាយតម្លៃពីលក្ខណៈសម្បត្តិពីសាមីអង្គភាព

**២. រយៈពេលសិក្សា**

- Architecture and Civil Engineering Master Program
  - រយៈពេលសិក្សាពីរឆ្នាំកន្លះ
- Master Degree for Electrical Engineering
  - រយៈពេលសិក្សាបីឆ្នាំ
- Master Degree Program in Water Conservancy Engineering
  - រយៈពេលសិក្សាពីរឆ្នាំកន្លះ

**៣. ការដាក់ពាក្យ និងកាលបរិច្ឆេទឈប់ទទួលពាក្យ៖**

និយោជិតអគ្គិសនីកម្ពុជាដែលមានបំណងចង់ដាក់ពាក្យស្នើសុំអាហារូបករណ៍ថ្នាក់អនុបណ្ឌិត សូមចូលទៅកាន់គេហទំព័ររបស់អគ្គិសនីកម្ពុជា **www.edc.com.kh/scholarship** ដើម្បីទទួលពាក្យស្នើសុំ និងបញ្ជូនមកការិយាល័យមូលនិធិសង្គម និងអាហារូបករណ៍ឲ្យបានមុនថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូមនិយោជិតអគ្គិសនីដែលមានបំណងចង់បន្តការសិក្សាថ្នាក់អនុបណ្ឌិតនេះ និងមានលក្ខណៈសម្បត្តិសមស្របសូមរួសរាន់ដាក់ពាក្យជាបេក្ខភាពតាមការគួរ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន:</u>

-អគ្គនាយករង អគ្គិសនីកម្ពុជា

-ឯកសារ - កាលប្បវត្តិ